# មេរៀន
# ស្តីពី
# ព្រះរាជគោរម្យនាមរបស់ព្រះមហាក្សត្រ

# បទបញ្ញាញ្ញ
# ស្តីពី

- ព្រះនាម
- ព្រះគោរម្យនាម
- ព្រះមរណនាមនិង
- ព្រះរាជបរមងារបស់ព្រះមហាក្សត្រ

ផ្អែកតាមប្រពៃណីទំនាមទំលាប់និងព្រះរាជពង្សាវតារខ្មែរ ព្រះមហាក្សត្រដែលបានគ្រងរាជសម្បត្តិ តែងមានព្រះនាម៣(បី)ជាផ្លូវការៈ

១- ព្រះនាមពីកំណើត

២- ព្រះគោរម្យនាមក្នុងអំឡុងគ្រងរាជ្យ

៣- ព្រះមរណនាមឬព្រះគោរម្យនាមក្រោយពេលចូលទីវង្គត

ឧទាហរណ៍ទី១: ព្រះមហាក្សត្រ **នរោត្តម សុរាម្រឹត**

១- ព្រះនាមពីកំណើត: **នរោត្តម សុរាម្រឹត**

២- ព្រះគោរម្យនាមក្នុងពេលគ្រងរាជ្យ:

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សុរាម្រឹត**

**វិសុទ្ធមហាខត្តិយវង្ស វិសិដ្ឋហរិវង្ស គុណាតិរេក**

**ធម្មចរិយោត្តម បរមនាថ បរមបពិត្រ**

**ព្រះចៅព្រះរាជអាណាចក្រកម្ពុជា ជាម្ចាស់ជីវិតលើត្បូង**

៣- ព្រះមរណនាមក្រោយពេលចូលទីវង្គត: **ព្រះមហាកញ្ញូនភោដ្ឋ**(កោដ្ឋមាសដ៏ធំ ដ៏ឧត្តម)

ឧទាហរណ៍ទី២: ព្រះមហាក្សត្រ **នរោត្តម សីហនុ**

១- ព្រះនាមពីកំណើត: **នរោត្តម សីហនុ**

២- ព្រះគោរម្យនាមក្នុងពេលគ្រងរាជ្យ:

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិក មហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

៣- ព្រះមរណនាមក្រោយពេលចូលទីវង្គត: **ព្រះបរមរតនកោដ្ឋ**(កោដ្ឋមាសដ៏ធំ ដ៏ឧត្តម)

**ស្វែងយល់ពីពាក្យពេជន៍ក្នុងព្រះគោរម្យនាម៖**

- **ពាក្យវ្រ័ន** (ជាខែលសម្រាប់ការពារ) ពាក្យនេះ ត្រូវបានព្រះមហាក្សត្រទ្រង់ព្រះរាជាអនុញ្ញាតឱ្យលុបចេញហើយ។
- **រាជហរិវង្ស** (រាជ+ហរិវង្ស) ស្តេចឬព្រះមហាក្សត្រ+ព្រះអាទិត្យឬព្រះនារាយណ៍ឬព្រះឥន្ទ្រ+ពង្ស=ពូជ

- **ឧភតោសុជាត** (ឧបតោ=ទាំងសងខាង+សុ+ជាត=ជាតកំណើតដ៏ល្អប្រពៃណី អ្នកកើតមកពីមាតាបីតាទាំងសងខាងមានពូជពង្សស្មើគ្នា(ក្សត្រដូចគ្នា)។ តាមវចនានុក្រមរបស់សម្ដេចសង្ឃ ជួន ណាត ពាក្យ **ឧបតោសុជាត** គ្មានស្រះ «ិ» លើ «**ត**» ទេ។
- **វិសុទ្ធពង្ស** (វិសុទ្ធ=ស្អាតវិសេសឬបរិសុទ្ធឥតមានហ្មង+វង្សឬពូជ=សន្តាន វិសុទ្ធពង្ស=ជាពូជពង្សឬត្រកូលដ៏វិសេសបរិសុទ្ធ។វិសុទ្ធពង្សឬវិសុទ្ធសន្តាននៅក្នុងវចនានុក្រមសម្ដេចសង្ឃ ជួន ណាត សរសេរគ្មានស្រះ «ិ» នៅលើពាក្យ «**សុទ្ធ**» ទេ។ សូមមើលលំនាំពាក្យ ប្រសិទ្ធភាព សមិទ្ធផល វិសុទ្ធកម្ម (ធ្វើឱ្យសុទ្ធ)...។ល។
- **អគ្គមហាបុរសរតន៍** (អគ្គ+មហា+រតន៍=កែវឬថ្មដ៏មានតំលៃ) បានសេចក្ដីថា កំពូលបុរសឧត្តម មានបញ្ញាបាជី ចែងចាំងដូចត្បូងពេជ្រពណ្ណរាយ។
- **និករោត្តម** (និករ=មនុស្សឬសត្វលោក)+ឧត្តម=ប្រសើរខ្ពង់ខ្ពស់
- **ធម្មិក** (អ្នកមានធម៌ឬមនុស្សប្រកបដោយធម៌)
- **មហារាជាធិរាជ** (មហា+រាជ+អធីរាជ)
- **បរមនាថ** (បរម=ប្រសើរខ្ពង់ខ្ពស់ក្រៃលែង+នាថ=ជាទីពឹង ជាពំនឹង ពឹងផ្អែក
- **បរមបពិត្រ** (បរម បពិត្រ=អ្នកដែលមានសម្បត្តិជាគ្រឿងនាំឱ្យមានចិត្តរីករាយឬឆ្អែតឆ្អន់ដោយទ្រព្យសម្បត្តិ
- ពាក្យ សូមសម្ដេចជា **អម្ចាស់**= ភាសានិយាយនិងពាក្យបុរាណដែលផ្សំឡើងរវាងពាក្យ **អង្គ+ម្ចាស់**=អម្ចាស់ យោងតាមសារាចររបស់ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រដែលចុះហត្ថលេខាដោយ ឯកឧត្តម **ទៀង មាលី** ជានាយកព្រះរាជខុទ្ទកាល័យ ក្នុងការឆ្លើយឆ្លងជាសារលិខិត បានណែនាំឱ្យសរសេរដូចខាងក្រោម:

**សូមចាប់ផ្ដើមលិខិតដូចនេះ៖**

  - **ព្រះករុណាជាម្ចាស់ជីវិតលើត្បូងឬ**
  - **ព្រះករុណាថ្លៃវិសេសឬ**
  - **ព្រះករុណា**

## ឧទាហរណ៍ទី៣: ព្រះមហាក្សត្រ **នរោត្តម សីហមុនី**

១- ព្រះនាមពីកំណើត: **នរោត្តម សីហនុ**

២- ព្រះគោរម្យនាមក្នុងពេលគ្រងរាជ្យ:

**ព្រះគោរម្យនាម**

បន្ទាប់ពីព្រះបិតាទ្រង់សម្ដេចព្រះ **នរោត្តម សីហនុ** ទ្រង់ដាក់រាជ្យសម្បត្តិ ព្រះអង្គត្រូវបានក្រុមប្រឹក្សារាជសម្បត្តិ ជ្រើសតាំងជាឯកច្ឆ័ន្ទ ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបន្តរាជ្យពីព្រះបិតា។

ព្រះរាជពិធីរាជាភិសេកព្រះអង្គជាផ្លូវការ ត្រូវបានប្រារព្ធឡើងនៅក្នុងព្រះបរមរាជវាំងក្រុងភ្នំពេញ នាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤។

ព្រះបរមនាមក្នុងរាជ្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** គឺ៖

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ព្រះរាជគោរម្យងារប្រែសេចក្ដីថា៖**

"អ្នកបម្រើមាតុភូមិ សាសនា ប្រជាជាតិ និងប្រជារាស្ត្រខ្មែរ ដោយស្វាមីភក្តិនិងភក្ដីភាព។ មហាក្សត្រ ដែលព្រះពុទ្ធនិងព្រះឥន្ទ្រលោកឧបត្ថម្ភ។ អ្នករួបរួមខេមរជនទាំងអស់។ អ្នកការពារឯករាជ្យ បូរណភាពទឹកដី និងសន្តិភាពរបស់កម្ពុជា ព្រមទាំងសុភមង្គល សេរីភាព និងវិបុលភាពរបស់ប្រជារាស្ត្រខ្មែរ។"

ព្រះនាមរបស់ព្រះអង្គ គឺបានមកពីការផ្សំគ្នារវាង ព្រះនាមរបស់ព្រះមាតាបិតាព្រះអង្គគឺ **សីហ** (សីហនុ) និង **មុនី**(មុនីនាថ)។

«**ព្រះស្រីលោកធម្មិករាជ**»

- ស្រង់ចេញពីសារព័ត៌មានFresh News ចេញផ្សាយថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥ មានចំណងជើងថា ទស្សនារូបភាពនៃព្រះរាជពិធីដង្ហែព្រះរាជបរមងារ «**ព្រះស្រីលោកធម្មិករាជ**» ថ្វាយព្រះមហាក្សត្រ អង្គការអន្តរជាតិផ្នែកព្រះពុទ្ធសាសនា តំណាងដោយសម្តេចព្រះសង្ឃរាជ ៣អង្គ មកពីប្រទេស៖

១- ម៉ុងហ្គោលី

២- សិង្ហបុរី

៣- ជប៉ុន

**ព្រះរាជបរមងារ**«**ព្រះស្រីលោកធម្មិករាជ**»មានន័យសម្រាយថា **ព្រះរាជាមានគុណធម៌ដ៏ខ្ពង់ខ្ពស់បំផុត ជាគំរូក្នុងការប្រតិបត្តិនិងផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធលើសកលលោក**។ ព្រះរាជបរមងារ ត្រូវបានសម្រេចថ្វាយព្រះមហាក្សត្រខ្មែរ ក្នុងមហាសន្និបាតព្រះពុទ្ធសាសនាពិភពលោកលើកទី៦ នៅប្រទេសជប៉ុន កាលពីខែធ្នូ ឆ្នាំ២០១៤។ (អាចជាឯកសាររដ្ឋបាល ប្រភេទជា សញ្ញាបត្រ)

នៅព្រឹកថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥នេះ បាននាំយកព្រះរាជបរមងារ «ព្រះស្រីលោកធម្មិករាជ» ថ្វាយព្រះមហាក្សត្រខ្មែរ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី។ ព្រះពិធីប្រគល់ព្រះរាជបរមងារ ដល់ព្រះមហាក្សត្រខ្មែរ ក៏មានការអញ្ជើញចូលរួមពីសម្តេច ហេង សំរិន ប្រធានរដ្ឋសភានិងភរិយា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា ព្រមទាំងមន្ត្រីជាន់ខ្ពស់រដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលជាច្រើនរូបទៀត។

ព្រះរាជពិធីដង្ហែព្រះរាជបរមងារ ត្រូវបានធ្វើឡើងយ៉ាងមហោឡារិកនិងមហាស្ចារ្យ ដោយមានការនិមន្តនិងអញ្ជើញចូលរួមពីសម្តេចគណៈសង្ឃ ព្រះមេគណ ព្រះសង្ឃ ប្រធានមន្ទីរធម្មការ និងសាសនា គ្រប់ខេត្ត-រាជធានី និងក្រសួងស្ថាប័នចំនួន៥៧ ព្រមទាំងយាយជី តាជី និងប្រជាពុទ្ធបរិស័ទយ៉ាងច្រើនកុះករ។ បន្ទាប់ពីបញ្ចប់ការដង្ហែ ក៏មានការរាប់បាត្រប្រគេនចង្ហាន់ព្រះសង្ឃប្រមាណ ១ម៉ឺនអង្គផងដែរ។

ព្រះរាជពិធីដង្ហែព្រះរាជបរមអដ្ឋិធាតុ នៅព្រឹកថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥នេះ បានចាប់ផ្ដើមពីម៉ោង៧ព្រឹករហូតដល់ម៉ោង១១៖០០នាទី។ អំឡុងពេលដង្ហែ ចរាចរណ៍លើកំណាត់ផ្លូវមួយចំនួនជុំវិញព្រះបរមរាជវាំង និងកន្លែងប្រារព្ធព្រះរាជពិធីត្រូវបានបិទទាំងស្រុង។ កំណាត់ផ្លូវដែលបិទចរាចរណ៍នោះ មានដូចជា វិថីព្រះស៊ីសុវត្ថិ ផ្លូវលេខ១៧៨ ផ្លូវលេខ១៩ មហាវិថីព្រះសុរាម្រិត មហាវិថីព្រះនរោត្តម ចាប់ពីរង្វង់មូលវិមានឯករាជ្យ រហូតដល់ផ្លូវ២៩៤ វិថីសុធារស និង រង្វង់មូលសម្ដេចព្រះសង្ឃរាជជួនណាត ។

ដោយឡែកចាប់ពីម៉ោង១៨និង០០នាទី រហូតដល់ម៉ោង២០និង០០នាទី បិទចរាចរណ៍គ្រប់យានយន្ត និងកាណូតទេសចរណ៍គ្រប់ប្រភេទដែលធ្វើចរាចរតាមដងទន្លេចតុមុខ ដើម្បីអុជកាំជ្រួចនៅមុខបរមរាជវាំង ហើយផុតរយៈពេលកំណត់នេះ នឹងអនុញ្ញាតឱ្យចរាចរជាប្រក្រតីឡើងវិញ។


World Buddhist Supreme Conference
His Majesty Norodom Sihamoni
King of the Kingdom of Cambodia
Honorary Title
"PREAH SRI LOKA DHAMMIKA RAJA"

# សូមអរគុណ